ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ :...៣០/១៨...ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) មានកិត្តិយសសូមជម្រាបជូនដល់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករ និយោជិត ឲ្យបានជ្រាបថា រាល់ស្ថានភាពរបស់កម្មករ និយោជិត ដែលមានអាការៈ ខ្សោយ វិលមុខ ទន់ដៃទន់ជើង ញ័រទ្រូង ពិបាកដកដង្ហើមនិងថប់អារម្មណ៍(Trouble Anxious / Generalize Anxiety Disorder) ដែលបណ្តាលមកពីខ្វះជាតិស្ករក្នុងឈាម (Hypoglycemia /Pseudohypoglycemia) ឬខ្វះសារធាតុអ៊ីយ៉ុងក្នុងឈាម មានដូចជា កាល់ស្យូម(Hypocalcemia) សូដ្យូម(Hyponatremia) ប៉ូតាស្យូម(Hypokalemia) ម៉ាញ៉េស្យូម (Hypomagnesemia) ដែលជាទូទៅ និយោជក ឬកម្មករនិយោជិតយល់ថា ជាស្ថានភាពសន្លប់ជាបុគ្គល ក្នុងកន្លែងធ្វើការ ឬម៉ោងធ្វើការ ហើយចាត់ទុកថាករណីបែបនេះជាគ្រោះថ្នាក់ការងារ។

ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៨ រាល់ស្ថានភាពរបស់កម្មករ និយោជិត ដូចបានរៀបរាប់ខាងលើ ប.ស.សចាត់ទុកថា ជាបញ្ហាសុខភាពផ្ទាល់ខ្លួនរបស់បុគ្គល មិនមែនបណ្តាលមកពីការងារឬបរិយាកាសកន្លែងធ្វើការទេ។ ដូច្នេះកម្មករ និយោជិតទាំងអស់ ត្រូវទទួលការព្យាបាល និងថែទាំវេជ្ជសាស្ត្រក្រោមរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពវិញ។

ក្នុងករណីមានកម្មករ និយោជិត សន្លប់ច្រើននាក់ ឬ សន្លប់តៗគ្នា នៅក្នុងសហគ្រាស គ្រឹះស្ថាន ដែលបណ្តាលមកពីបរិយាកាសក្នុង និងក្រៅ សហគ្រាសគ្រឹះស្ថាន ឬតានតឹងអារម្មណ៍ ភ័យស្លន់ស្លោ តៗគ្នា ។ល។ បេឡាជាតិរបបសន្តិសុខសង្គមចាត់ទុកថាជាគ្រោះថ្នាក់ការងារ និងទទួលបានការព្យាបាល និងថែទាំវេជ្ជសាស្ត្រ ក្រោមរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចបញ្ជូនកម្មករ និយោជិតរបស់ខ្លួនទៅសង្គ្រោះបឋមនៅគិលានដ្ឋានសហគ្រាសរបស់ខ្លួន ឬទៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមនាយក ម្ចាស់ សហគ្រាស គ្រឹះស្ថាន និងកម្មករ និយោជិតទាំងអស់មេត្តាជ្រាប និងអនុវត្តតាមសេចក្តីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម**

អ៊ុក_សមវិទ្យា

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៨៨ ១០ ១៥ ០២៣-៨៨ ១០ ១៦ , ០២៣ ៨៨ ០៤ ១៧
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh